# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ
## ក្រោមប្រធានបទ ការព្យាបាលរោគផ្លូវចិត្ត (ត)

website ៖ www.hoksavann.org

ថ្ងៃទី១៣ មករា ២០០៩



### ពិចារណាកម្មផល
### ទុក្ខផ្លូវចិត្តនឹងត្រូវរលត់

វិបត្តិខ្លះមានសភាពដ៏ធ្ងន់ ដែលមិនអាចវិលត្រឡប់ឲ្យដូចដើមវិញ ដូចសមាជិកគ្រួសារបានទទួលមរណភាព ពុំអាចរស់ឡើងវិញបាន ធ្វើឲ្យបុគ្គលដែលពុំបានពិចារណាតាមផ្លូវធម៌ មានការកើតទុក្ខផ្លូវចិត្តយ៉ាងខ្លាំង ដោយការសោកស្តាយនូវជន ដែលជាទីស្រឡាញ់របស់ខ្លួន ។ សេចក្តីទុក្ខបែបនេះបានត្រូវរលត់ បើបុគ្គលពិចារណាតាមផ្លូវធម៌ថា របស់អ្វីទាំងអស់ទាំងមានវិញ្ញាណទាំងឥតវិញ្ញាណ ដែលតែងស្លាប់និងបាត់បង់ទៅតាមកម្មផលរបស់ខ្លួន ហើយការព្រាត់ប្រាស់គ្នាក៏តែងមានជាធម្មតា ។ ការយំសោកស្តាយក៏ពុំអាចរស់ឡើងវិញបានឡើយ ថែមទាំងធ្វើឲ្យជីវិតរបស់ខ្លួនដែលកំពុងរស់នៅមានទុក្ខថែមទៀត ។

ព្រះពុទ្ធបានសំដែងធម៌ទេសនាប្រោសនាងបដាចារា ដែលមានទុក្ខជាទម្ងន់ ដោយជនជាទីស្រឡាញ់របស់នាងបានទទួលមរណភាព មានសេចក្តីដំណាលដោយសេចក្តីសង្ខេបថា នាងបដាចារាជាបុត្រីមហាសេដ្ឋីម្នាក់ បានស្រឡាញ់បុរសជាខ្ញុំបំរើម្នាក់នៅក្នុងផ្ទះ ហើយទាំងពីរនាក់បានលួចរត់ទៅនៅក្នុងជនបទមួយ ព្រោះខ្លាចមាតាបិតា ។ រស់នៅជាមួយប្តីអស់កាលជាច្រើនឆ្នាំ នាងបដាចារាសម្រាលបានកូនពីរនាក់ ។ ថ្ងៃមួយបុរសជាប្តីទៅរកអុស ត្រូវពស់មានពិសចឹកស្លាប់នៅក្នុងព្រៃគុម្ពោតមួយ ។ នាងបានឃើញហើយ ក៏ទ្រហោយំ

សោយសោកស្តាយប្តីដែលកំសត់កម្រជាមួយគ្នា បានត្រូវបាត់បង់ជីវិត ។ ដោយអស់ទីពឹង នាងក៏សំរេចចិត្តធ្វើដំណើរទៅភូមិកំណើត បំណងទៅសុំទោសមាតាបិតាឲ្យលើកទោសឲ្យនាង ដោយដឹកដៃកូនបងពកូនប្អូន ។ នាងបានធ្វើដំ-ណើរឆ្លងស្ទឹងមួយដែលមានទឹករាក់ល្មមសំរាប់មនុស្សចាស់ ។ នាងមិនអាចយកកូនទាំងពីរទៅជាមួយគ្នាតែម្តងបានឡើយ នានបានទុកកូនធំនៅត្រើយម្ខាង ពកូនតូចទៅដាក់ត្រើយម្ខាងមុន ។ លុះដាក់កូនតូចរួចហើយ ក៏ត្រឡប់មកយកកូនធំ ។ ជាអកុសល នាងដើរមកដល់ពាក់កណ្តាលស្ទឹង ស្រាប់តែមានសត្វឥន្ទ្រីយ៍ដ៏ធំមួយបោះពួយឆាបយកកូនរបស់នាងហើរបាត់ទៅ ។ នាងភ័យណាស់ ខំលើកដៃទាំងពីរទទះបង្អើលសត្វផង ស្រែកយ៉ាងខ្លាំងផង ។ ឯកូនធំដែលនៅត្រើយម្ខាង ស្មានតែម្តាយបក់ដៃហៅខ្លួន ក៏ដើរចុះទៅក្នុងទឹក ត្រូវខ្សែទឹកកួចបាត់ទៅ ។ ឃើញទិដ្ឋភាពដ៏រន្ធត់ដូចនេះ នាងស្រឡាំងកាំងហាក់ដូចជាគ្មានស្មារតីក្នុងខ្លួន ខំឡើងមកលើគោកវិញដោយក្តីអស់សង្ឃឹម ។ នាងបានធ្វើដំណើរទៅមុខទៀតដោយគ្មានទិសដៅ ។ នៅតាមផ្លូវនាងភ្លេចស្មារតីម្តងៗ រត់ទៅឱបបុរសឃ្វាលគោម្នាក់ត្រូវគេច្រានដួល ដោយគេសំគាល់ថាជាមនុស្សឆ្កួត ។ លុះដឹងខ្លួនក្រោកឡើង ធ្វើដំណើរទៅទៀត ឃើញគេបីកូន ក៏ស្ទុះទៅឯណ្តើមកូនពីគេ ត្រូវគេច្រានដួលទៀត ។ នេះជាសញ្ញាខុសរបស់នាង វង្វេងថាជាប្តីនិងកូនរបស់នាង ។ ពេលមានស្មារតីដឹងខ្លួនម្តងៗ នាងស្រែកទ្រហោយំក្រៀមក្រំក្នុងចិត្ត ស្រែកហៅស្វាមីនិងបុត្រទាំងពីរ ។ នៅតាមផ្លូវ នាងបានទទួលដំណឹងដ៏ក្រៀមក្រំមួយទៀតពីឈ្មួញរទេះ ដែលមកពីក្រុងសាវត្ថី ថាម្តាយឪពុករបស់នាងបានទទួលមរណភាពទាំងពីរនាក់កន្លងមួយអាទិត្យហើយ ដោយគ្រោះថ្នាក់ខ្យ-ល់ព្យុះបក់បោករលំគេហដ្ឋានកិនស្លាប់ ។

ដោយកុសលផលបុណ្យជាឧបនិស្ស័យ ដែលនាងបានកសាងពីអតីតជាតិ បានជំរុញឲ្យនាងបោះជំហានឈានទៅដល់វត្តជេតពន ដែលជាអារាមរបស់ព្រះពុទ្ធជាម្ចាស់គង់នៅ ។ គាប់ជួនពេលនោះ ព្រះពុទ្ធបរមគ្រូកំពុងសំដែងធម៌ទេសនាតាមកម្មវិធីប្រចាំថ្ងៃក្នុងពុទ្ធកិច្ចទាំងប្រាំ ។ នាងបដាចាមានការហេវហត់អស់កម្លាំង ភ្នែកទាំងពីរជោគជាំដោយទឹកភ្នែក ទឹកមុខស្រងូតស្រងាត់ ខោអាវក្រខ្វក់ដាច់ដាច ខំបោះជំហានដោយសន្សឹមៗ ធ្វើដំណើរចូលទៅនៅក្នុងចំណោម

ពុទ្ធបរិស័ទដែលកំពុងស្តាប់ធម៌ ។ ពួកគេបានឃាត់ដំណើរនាងដោយមានគំនិតថា នាងនេះមានកាយសៅហ្មង ពុំគួរចូលមកជួបព្រះពុទ្ធទេ ។ បន្ទាប់ពីទតឃើញនាងហើយ ព្រះពុទ្ធមានព្រះពុទ្ធដីកាទៅកាន់ពុទ្ធបរិស័ទថា ចូរអ្នកទាំងឡាយកុំឃាត់នាងអី ចូរបើកផ្លូវឲ្យនាងចូលមកជិតតថាគតចុះ ពេលនេះជាពេលសមគួរដល់នាងហើយ ។ ពេលចូលទៅជិតព្រះពុទ្ធ ទើបនាងមានស្មារតីរលឹកឃើញកាលនាងនៅពីតូចថា នេះជាតួអង្គព្រះពុទ្ធ ដែលកាលនាងនៅជាកុមារី តែពុកម្តាយនាងពោលសរសើរអំពីគុណធម៌ និងធម៌ទេសនារបស់ព្រះអង្គ ប៉ុន្តែពេលនោះ នាងនៅតូចពេកមានការរៀនខ្វាស់ច្រើន ពុំបានយកចិត្តទុកដាក់ស្តាប់ធម៌ទេសនាព្រះអង្គទេ ។ នាងលុតជង្គង់បង្អោនខ្លួនថ្វាយបង្គំព្រះពុទ្ធជាម្ចាស់ដោយសេចក្តីគោរពដ៏ជ្រាលជ្រៅបំផុតក្នុងអាការៈថា សូមព្រះពុទ្ធជាកំពូលនៃអ្នកប្រាជ្ញមេត្តាប្រោសនាងខ្ញុំព្រះអង្គដែលកំពុងមានទុក្ខដ៏ធ្ងន់ផង ។ ព្រះពុទ្ធជាម្ចាស់ត្រាស់ថា នាងបដាចាចូរក្រោកឡើង តាំងស្មារតីឲ្យរឹងមាំ ពិចារណានូវខន្ធប្រាំដែលកើតឡើងហើយ ត្រូវរលត់ទៅវិញ ហើយការព្រាត់ប្រាស់គ្នាក៏តែងមានជាធម្មតាចំពោះមនុស្សសត្វនៅក្នុងភពបី ។ ចូរនាងដកចិត្តចេញពីជនទាំងឡាយដែលជាទីស្រឡាញ់របស់នាងដែលបាត់បង់ជីវិតទៅ ព្រោះគេទាំងឡាយប្រព្រឹត្តទៅតាមអំពើរបស់គេហើយ ។ ចូរនាងក្រឡេកមកមើលខ្លួនរបស់នាងវិញ ព្រោះខ្លួននាងពុំខុសពីជនទាំងនោះដែរ សត្វលោកប្រព្រឹត្តទៅតាមអំពើរបស់ខ្លួន ។

(នៅមានត)

❄ ❄

❄